**ព្រះរាជាណាចក្រ កម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
**សភាផ្នែករដ្ឋប្បវេណី**
សំណុំរឿង រដ្ឋប្បវេណី
លេខ:៣៥៥
ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨
**សាលដីកា**
លេខ:១១៣
ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**
បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ ដោយមានសមាសភាពដូចតទៅៈ
១-ឯកឧត្តម **ឌិត មន្ទី** ជាប្រធាន
២-លោក **ប៉ែន ស៊ុន** ជាចៅក្រម
៣-លោក **វៀល មួន** ជាចៅក្រម
៤-លោក **ស៊ិន ឌឹម** ជាចៅក្រមរបាយការណ៍
៥-លោក **ជីវ កេង** ជាចៅក្រម

**ក្រឡាបញ្ជី**
-លោក **ទៀវ ដាណា**

**តំណាងមហាអយ្យការ**
-លោក សាយ សារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ៦១៩ ចុះថ្ងៃទី១៧-០៩-៩៨ នៃសំណុំរឿង រដ្ឋប្បវេណីលេខ០៣ ចុះថ្ងៃទី១៧-០៥-៩៤ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះនង ស៊ុំ ភេទប្រុសអាយុ៤០ឆ្នាំជាតិខ្មែរ មុខរបរ ធ្វើនគរបាលមានទីលំនៅផ្ទះលេខ១៩១AE$_1$ ផ្លូវលេខ១៨២ ក្រុមទី២០ សង្កាត់ទឹកល្អក់ ខណ្ឌទួលគោក ។ ឪពុកឈ្មោះនង យី (ស) ម្តាយឈ្មោះខៀវ គូ (ស) ប្រពន្ធឈ្មោះហ៊ឹម ដាលី មានកូន០៣នាក់ ។

ម្ចាស់បណ្តឹងសាទុក្ខឈ្មោះគ្រាន់ ឆាយឃៀង ភេទប្រុសអាយុ៣៥ឆ្នាំ ជាតិខ្មែរ មានទីលំនៅផ្ទះលេខ០១A ផ្លូវលេខ២៥៩ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក ក្រុងភ្នំពេញ ។

មានមេធាវីឈ្មោះលោក ហេង ដី

និងចុងបណ្តឹងសាទុក្ខឈ្មោះប្រាក់ សន ភេទប្រុសអាយុ ៥៣ឆ្នាំ ជាតិខ្មែរមុខរបរធ្វើការនៅក្រសួងពាណិជ្ជកម្ម មានទីលំនៅផ្ទះលេខ១៥៨ ផ្លូវលេខ១៤៣ ក្រោយរោងកុនគីរីរម្យ សង្កាត់អូឡាំពិក ខណ្ឌចំការមន ក្រុងភ្នំពេញ ។ ឪពុកឈ្មោះប្រាក់ នុក (ស) ម្តាយឈ្មោះគង់ ណៃ( ស )ប្រពន្ធឈ្មោះចាន់ ថន មានកូន ០៩នាក់ ។

មានមេធាវីលោក សូ អ៊ីន

**កម្មវត្ថុបណ្តឹង** ប្តឹងសុំសិទ្ធិកាន់កាប់ដីឡូត៍លេខ១៤៤

បានឃើញបណ្តឹងសាទុក្ខលេខ៣៨៧ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៩៨ របស់ឈ្មោះត្រាន់ ឆាយយៀង និងបណ្តឹងសាទុក្ខលេខ៣៨៨ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៩៨ បានប្តឹងមិនសុខចិត្ត នឹងសេចក្តីសម្រេចនៃសាលដីកាលេខ៦១៩ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៣៥៥ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១៧-០១-៩២ របស់ឈ្មោះប្រាក់ សន ជាដើមចោទថាៈ ខ្លួនប្តឹងទាមទារដីឡូត៍លេខ១៤៤ ផ្លូវលេខ២១៥ សង្កាត់វាលវង់ ខណ្ឌ៧មករា ពីឈ្មោះនង ស៊ុំ ជាចុងចម្លើយដោយសំអាងហេតុថា ខ្លួនបានកាន់កាប់ដីឡូត៍នេះពីឆ្នាំ១៩៨៤ ដោយមានសេចក្តីអនុញ្ញាតិត្រឹមត្រូវពីក្រសួងឧស្សាហកម្ម ហើយប្រពន្ធរបស់ខ្លួនបានអនុញ្ញាតិឱ្យចុងចម្លើយស្នាក់នៅបណ្តោះអាសន្ននៅឆ្នាំ១៩៨៦ ទំរាំនឹងរកផ្ទះបាន នៅពេលដែលខ្លួនជាប់រៀននៅវៀតណាម ។ នៅពេលដែលខ្លួនត្រឡប់មកវិញ ខ្លួនបានប្រាប់ នង ស៊ុំ ឱ្យរកកន្លែងរស់នៅផ្សេង ដែរ តែប្រពន្ធខ្លួនប្រាប់ថា ឱ្យនៅចាំដីផងទៅ ។ ស្រាប់តែពេលនេះ ចុងចម្លើយមិនព្រមចុះចេញ ថែមទាំងលួច ធ្វើកម្មសិទ្ធិ រួចលក់ដីកើតហេតុនេះ ឱ្យនៅអ្នកផ្សេងទៀតផង ។

បានឃើញសាលក្រមលេខ១៤៤ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៩២ របស់តុលាការក្រុងភ្នំពេញដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១- ទទួលពាក្យបណ្តឹង ចុះថ្ងៃទី១៧-០១-៩២ រប់ឈ្មោះប្រាក់ សន ដើមចោទទុកជាត្រឹម ត្រូវតាមច្បាប់ តែផ្ទុយនឹងគតិច្បាប់។

២- ទទួលពាក្យបណ្តឹងចុះថ្ងៃទី០២-០២-៩២ របស់ឈ្មោះនង ស៊ុំ ជាចុងចម្លើយ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

៣- ប្រគល់ដីឡូត៍លេខ១៤៤ ផ្លូវ២១៥ សង្កាត់វាលវង់ ខណ្ឌ៧មករា ក្រុងភ្នំពេញ ឱ្យទៅឈ្មោះនង ស៊ុំ កាន់កាប់តាំងពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។ សំណូមពរចុងចម្លើយលើសពីនេះ ត្រូវបដិសេធចោល ។

៤. សាលក្រមនេះជំនុំជំរះជាសាធារណៈ ចំពោះមុខគូក្តី សម្រេចជាលើកទី១ និងជាលើកចុងក្រោយ បង្អស់ ។ ( ឯ.១៤១ )

បានឃើញបណ្តឹងឧទ្ធរណ៍លេខ៣២១ ចុះថ្ងៃទី២៧-០៨-៩២ របស់លោកប្រាក់ សន ដែលប្តឹងជំទាស់នឹងសាលក្រមលេខ១៤៤ ចុះថ្ងៃទី២៤-០៧-៩២ របស់តុលាការក្រុងភ្នំពេញ លើសេចក្តីសម្រេចទាំងមូល ។(ឯ.១២២)

បានឃើញសេចក្តីសម្រេចលេខ០១.៩៣.ក.ព.ហក្រ.ក្រ ចុះថ្ងៃទី១៩-០៤-៩៣ សម្រេចៈ

របៀបវារៈ មាន៤ ក្នុងនោះរបៀបវារៈទី៤ ដែលពាក់ព័ន្ធក្នុងរឿងនេះ ហើយចៅក្រមប្រឹក្សា បានសម្រេចធ្វើសំណើទៅគណៈអចិន្ត្រៃយ៍ នៃរដ្ឋសភាឱ្យបកស្រាយមាត្រា៦៣ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ។(ឯ. ១៤៤ ១ទ៣៨)។

រឿងនេះ ក្រោយពីបានបង្វិលទៅតុលាការក្រុងភ្នំពេញសម្រេចហើយ លោក ប្រាក់ សន បានប្តឹងឧទ្ធរណ៍ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៩៨ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៩៤ របស់សាលា ឧទ្ធរណ៍ សម្រេចចំពោះមុខចុងបណ្តឹងឧទ្ធរណ៍ និងកំបាំងមុខដើមបណ្តឹងឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១- ទទួលបណ្តឹងឧទ្ធរណ៍របស់ឈ្មោះប្រាក់ សន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់ខុស នឹងគតិច្បាប់ ។

២- តម្កល់សាលក្រមលេខ១៤៤ ចុះថ្ងៃទី២៥-៧-៩២ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការពេញទាំងមូល ។

៣-សម្រេចឲ្យប្រាក់ សន និងនាងចាន់ ថន សងជម្ងឺចិត្តចំនួន៥០០០ ដុល្លារ ឲ្យទៅនាង ស៊ុំ ។ សំណូមពរលើសពីនេះលើកចោល ។

៤-រឹបអូសប្រាក់ប្រដាប់ក្តី១៣០០០៛ ដែលប្រាក់ សន បានបង់ទុករួចហើយ ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ រង្វាន់អ្នកប្រគល់ដីកាកោះ៥០០០៛ អាជ្ញាធរតុលាការ៥០០០៛ ។

កាលបើផុតកំណត់ប្តឹងឧទ្ធរណ៍បង្គាប់ឲ្យប្រាក់ សន បង់ពន្ធសមាមាត្រ១%លើប្រាក់ជម្ងឺចិត្ត ៥០០០ដុល្លារ ស្មើនឹង៥០ដុល្លារ ប្រាក់នេះត្រូវបានថវិការដ្ឋ៨០% និងរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០% ។

៥- សាលដីកានេះ ប្រកាសជាសាធារណៈចំពោះមុខចុងបណ្តឹងឧទ្ធរណ៍ កំបាំងមុខដើមបណ្តឹងឧទ្ធរណ៍ បើកផ្លូវប្តឹងទាស់ និងប្តឹងសាទុក្ខ តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ០៣ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៩៤ របស់ឈ្មោះលោកប្រាក់ សន បានប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ៩៨ ចុះថ្ងៃទី១១ វិច្ឆិកា ឆ្នាំ១៩៩៤ របស់សាលាឧទ្ធរណ៍ លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីកាព្រហ្មទណ្ឌលេខ១៩ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៩៧ របស់តុលាការកំពូល សម្រេចចំពោះមុខជនជាប់ចោទ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខដើមបណ្តឹង រដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១- ទទួលបណ្តឹងសាទុក្ខលេខ១៦០ ចុះថ្ងៃទី០១-០៧-៩៧ របស់ឈ្មោះនង ស៊ុំ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២- ទុកជាមោឃៈ សាលដីកាព្រហ្មទណ្ឌលេខ៦៣ ចុះថ្ងៃទី២៦-០៦-៩៦ របស់សាលាឧទ្ធរណ៍ទាំងមូល ដោយឥតបង្វិល ។

៣- ឱ្យជនជាប់ចោទឈ្មោះនង ស៊ុំ រួចពីការចោទប្រកាន់ពីបទប្រើប្រាស់លិខិតក្លែង ។

៤- សាលដីការនេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៤-០៧-៩៧ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៦១៩ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍សម្រេចចំពោះមុខគូក្តី ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១- ទទួលបណ្តឹងទាស់ ចុះថ្ងៃទី២១-១១-៩៥ របស់ឈ្មោះប្រាក់ សន ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២- បដិសេធសាលក្រមរដ្ឋប្បវេណីលេខ១៤៤/២៤.០៧.៩២ របស់តុលាការក្រុងភ្នំពេញ និងសាលដីកាកំបាំងមុខលេខ៩៨/១១-១១-៩៤ របស់សាលាឧទ្ធរណ៍ចោលជាអាសារបង់ ហើយសម្រេចជាថ្មីដូចតទៅនេះៈ

ក- ប្រគល់ដីទំនាស់ឡូត៍លេខ១៤៤ ផ្លូវលេខ២១៥ ក្រុម៦២ សង្កាត់វាលវង់ ខណ្ឌ៧មករា ក្រុងភ្នំពេញ ឱ្យទៅឈ្មោះប្រាក់ សន និងនាងចាន់ ថន ចាប់ពីពេលសាលដីកាចូលជាស្ថាពរ ។

ខ-ទុកសិទ្ធិឱ្យឈ្មោះគ្រាន់ ឆាយឃៀង ប្តឹងទារប្រាក់ថ្លៃទិញដី និងជម្ងឺចិត្ត សោហ៊ុយបង់ខាតផ្សេងៗ ពីឈ្មោះនង ស៊ុំ ទៅតុលាការតាមច្បាប់ ។

៣- រឹបអូសប្រាក់ប្រដាប់ក្តីនៅជាន់សាលាឧទ្ធរណ៍ ដែលឈ្មោះប្រាក់ សន បានបង់រួចហើយ គឺពន្ធហ្មឹង និងពន្ធចុះបញ្ជីក្តី២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រៀល ចំណាយលើកិច្ចប្រគល់ ដីកាកោះ៥.០០០រៀល សរុប១៣.០០០រៀល ។

កាលបើផុតកំណត់ប្តឹងសាទុក្ខ បង្គាប់ឱ្យឈ្មោះនង ស៊ុំ សងប្រាក់១៣.០០០រៀល ទៅ ប្រាក់ សន វិញ និងឱ្យនង ស៊ុំ បង់ពន្ធសមាមាត្រ១% នៃមាស២៨៥តម្លឹង ដែលជាតម្លៃដីទំនាស់ ។ ប្រាក់នេះ ៨០% ត្រូវបានជាប្រយោជន៍ថវិកាជាតិ និង២០% ត្រូវបានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ។

៤- សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខចុងបណ្តឹងឧទ្ធរណ៍ឈ្មោះប្រាក់ សន នាងចាន់ ថន និងចំពោះមុខនង ស៊ុំ គ្រាន់ ឆាយឃៀង ជាចុងបណ្តឹងឧទ្ធរណ៍សម្រេចបើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៣៨៧ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ ១៩៩៨ របស់ឈ្មោះលោក គ្រាន់ ឆាយឃៀង និងបណ្តឹងសាទុក្ខលេខ៣៨៨ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៩៨ បានប្តឹងមិនសុខចិត្ត នឹង

សាលដីកាលេខ៦១៩ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៩៤របស់សាលាឧទ្ធរណ៍លើសេចក្ដីសម្រេចទាំងមូល ។

បានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្ដាប់សចក្ដីសន្និដ្ឋាន របស់តំណាងមហាអយ្យការ :

ក្រោយពីបានពិនិត្យគ្រប់ឯកសារពាក់ព័ន្ធរឿងក្ដីនេះ មកតំណាងមហាអយ្យការពិនិត្យឃើញថា: សាលាឧទ្ធរណ៍សម្រេចត្រឹមត្រូវតាមគតិច្បាប់ហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះសម្រេចតាមច្បាប់ ។

បានស្ដាប់ចម្លើយរបស់ឈ្មោះប្រាក់ សន ជាដើមចោទ និងជាចុងបណ្ដឹងសាទុក្ខ នៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា៖ រឿងលក់នេះ ខ្លួនពុំបានដឹងអ្វីទាំងអស់ ហើយនង ស៊ុំ បានក្លែងបន្លំក្រដាសស្នាមទាំងស្រុង ខ្ញុំគ្មានអ្វីបន្ថែមវែងឆ្ងាយទេ ខ្លួនចង់ឱ្យតុលាការមេត្តាផ្ដន្ទាទោសជនក្លែងបន្លំ ក្រដាសស្នាមដើម្បីយក របស់អ្នកដ៏ទៃទៅលក់ទាំងខុសច្បាប់ ។

បានស្ដាប់សេចក្ដីសន្និដ្ឋានមេធាវីដើមចោទឈ្មោះលោកសូ អ៊ីន

បានស្ដាប់ចម្លើយរបស់ឈ្មោះគ្រាន់ ឆាយឃៀង ជាចុងចម្លើយ និងជាដើមបណ្ដឹងសាទុក្ខ នៅពេលជំនុំជំរះ បានឆ្លើយបញ្ជាក់ថា : សាលាឧទ្ធរណ៍កាត់សេចក្ដីមិនយុត្តិធម៌ ។ កាលពីខែមករា ឆ្នាំ១៩៩២ ខ្លួនបានទិញដីពី នង ស៊ុំ ហើយឱ្យឃើញមានប័ណ្ណកម្មសិទ្ធិ ប័ណ្ណគ្រួសារទាំងអស់ ថាត្រឹមត្រូវអស់ហើយ ខ្លួនក៏ បានកក់លុយទៅគាត់ចំនួន៥.០០០ដុល្លារ ។ ក្រោយមកស្រាប់តែ ឮថាមានគេមកប្ដឹងថាដីនេះ ជារបស់គេទៅវិញ ក៏មានរឿងហេតុប្ដឹងផ្ដល់គ្នារហូតមក ។ ខ្លួនឥតមានអ្វីឆ្លើយទៀតទេ សុំឱ្យក្រុមប្រឹក្សាជំនុំជំរះមេត្តាជួយរកយុត្តិធម៌ ឱ្យខ្លួនផង ។

បានស្ដាប់សេចក្ដីសន្និដ្ឋានមេធាវីចុងចម្លើយឈ្មោះលោកហេង ជី ។

-ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់ចម្លើយដោះសារបស់គូភាគី និង សេចក្ដីសន្និដ្ឋានរបស់មេធាវីនៃគូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

– យល់ឃើញថា បណ្ដឹងសាទុក្ខលេខ៣៨៧ ចុះថ្ងៃទី២៩-១០-៩៨ របស់លោកគ្រាន់ ឆាយឃៀង និង បណ្ដឹងសាទុក្ខលេខ៣៨៨ ចុះថ្ងៃទី២៩-១០-៩៨ របស់លោកនង ស៊ុំ ស្ថិតនៅក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤នៃច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្ដី។

-យល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា លិខិតប្រគល់ប្រាក់ ចុះថ្ងៃទី០២-០៧-៨៦ ក្លែងបន្លំកាលបរិច្ឆេទក្នុងអំឡុងឆ្នាំ១៩៨៦ ហើយ រហូតដល់ថ្ងៃលក់ដីទំនាស់ឱ្យឈ្មោះយូ ងួន នាឆ្នាំ១៩៩០ ទើបដើមចោទដឹង ហើយបានប្តឹងជំទាស់ ដែលធ្វើឱ្យការលក់ទិញនេះ ត្រូវអាក់ខានទៅវិញ ។

- យល់ឃើញថា រាល់សំអាងរបស់ចុងចម្លើយ និងសារណាការពារចុះថ្ងៃទី១៨-០១-៩៩ របស់លោកត្រាន់ ឆាយឃៀង ទទួលសិទ្ធិពីលោកនង ស៊ុំ ដែលលើកឡើងថា ការលក់ទិញទំនាស់របស់លោកនង ស៊ុំ សុទ្ធតែត្រឹមត្រូវតាមបែបបទរដ្ឋបាលទាំងអស់នោះ ជាការភ័ន្តច្រឡំពីព្រោះថា៖

លិខិត ចុះថ្ងៃទី ០២-០៧-៨៦ ដែលមានផ្តិតមេដៃរបស់ភរិយាចោទនោះ មានភាពមិនប្រក្រតី ជាច្រើនអន្លើ និងមិនមានការយល់ព្រមពីដើមចោទដែលជាម្ចាស់ដី ធ្វើនៅពេលយប់ ពុំមានរដ្ឋអំណាចដឹងឮនោះត្រូវទុកជាមោឃៈតាមមាត្រា៦-៧ និង១០ នៃក្រិត្យច្បាប់លេខ៣៨ក្រ.ច ហើយ ។

យល់ឃើញថា លិខិតលក់ទិញដដែលនេះ សាក្សីបំភ្លឺឈ្មោះយ៉ែម ហែមរិទ្ធិ ដែលជារដ្ឋអំណាចមូលដ្ឋានបានឆ្លើយថា ការចុះហត្ថលេខាបញ្ជាក់ទើបធ្វើនៅឆ្នាំ១៩៩២ ។ ដូច្នេះការផ្ទេរកម្មសិទ្ធិត្រូវអនុវត្តតាមមាត្រា៤១ នៃក្រឹត្យ.ច្បាប់ខាងលើនេះដែរ និងតាមមាត្រា១៨២ នៃច្បាប់ភូមិបាលទើបទុកជាត្រឹមត្រូវបាន ។

-យល់ឃើញថា ចម្លើយរបស់ចុងចម្លើយបានឆ្លើយសារភាពនៅចំពោះមុខរដ្ឋអាជ្ញា អមតុលាការក្រុងភ្នំពេញ ក៏ដូចនៅសាលាឧទ្ធរណ៍ដែរថា អក្សរដែលសរសេរបន្ថែមលើ_ក្រោមពិតជាខ្លួនបានសរសេរបន្ថែមប្រាកដមែន ។

-យល់ឃើញថា ការណ៍ដែលតុលាការកំពូលសម្រេចឱ្យឈ្មោះនង ស៊ុំ ចុងចម្លើយជាជនល្មើសរួចខ្លួនពី បទចោទលើបញ្ហាបន្ទាន់បង្ហំនោះដោយសារអំពើក្លែងនេះ ស្ថិតក្រោមអំណាចនៃក្រឹត្យច្បាប់លេខ ០២ក្រ.ច ចុះថ្ងៃទី១៥-០៥-៨០ ដែលពុំបានចែងអំពីអំពើនេះតែប៉ុណ្ណោះ ។ ប៉ុន្តែសកម្មភាពជាក់ស្តែងដែលចុងចម្លើយប្រព្រឹត្តបានធ្វើ ឱ្យដើមចោទទទួលរងនូវព្យសនកម្មយ៉ាងពិតប្រាកដ ។

-យល់ឃើញថា ការណ៍ដែលមេធាវីចុងចម្លើយលើកឡើងថា ការណ៍ដែលតុលាការកំពូលពុំបានធ្វើការចោទប្រកាន់លោកនង ស៊ុំ នោះមានន័យថាលិខិតលក់ទិញចុះថ្ងៃទី០២-០៧-៨៦ មានសុពលភាពនោះជាការភ័ន្តច្រឡំពីព្រោះថា លោកនង ស៊ុំ ដែលរួចខ្លួនពីបទក្លែងនោះ ដោយអំពើរបស់ឈ្មោះនេះកើតឡើងមុនបទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការនីតិវិធីព្រហ្មទណ្ឌ ដែលត្រូវអនុវត្តនៅកម្ពុជា ចូលជាធរមានប៉ុណ្ណោះ ឯលិខិតដែលកើតឡើងពីអំពើនេះ ពុំអាចមានសុពលភាពបានឡើយ ។ ម្យ៉ាងទៀតការអះអាងថា លោក នង ស៊ុំ រស់នៅពីផ្ទះស្បូវរហូតនៅជាផ្ទះថ្មនោះ ក៏ជាការពុំត្រឹមត្រូវដែរ ពីព្រោះផ្ទះដែលអះអាងថា ធ្វើពីថ្មនេះ គឺគ្រាន់តែរៀបជញ្ជាំងលើលំនាំចាស់ដែល មានស្រាប់ប៉ុណ្ណោះ ហើយរាល់ការចាត់ចែងរបស់លោក នង ស៊ុំ ត្រូវបានដើមចោទប្តឹងជំទាស់ជាដរាប ។

-យល់ឃើញថា សាលដីកាវដ្តបុប្បវេណីលេខ៦១៩/១៧-០៩-៩៨ របស់សាលាឧទ្ធរណ៍ដែលសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី ចំពោះមុខគូក្តី**

១- ទទួលបណ្តឹងសាទុក្ខលេខ៣៨៧ ចុះថ្ងៃទី២៩-១០-៩៨ របស់លោក ត្រាន់ នាយឃៀង និងបណ្តឹងសាទុក្ខលេខ៣៨៨ ចុះថ្ងៃទី២៩-១០-៩៨ របស់លោក នង ស៊ុំ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ៦១៩ ចុះថ្ងៃទី១៧-០៩-៩៨ របស់សាលាឧទ្ធរណ៍ទុកជាបានការ ពេញទាំងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្តី ដែលលោកប្រាក់ សន បានបង់ទុកនៅតុលាការកំពូលចំនួន១៩០០០៛ គឺ៖

- ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

- ចំណាយក្នុងការប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ។ ហើយតម្រូវឱ្យលោកនង ស៊ុំ សងប្រាក់ចំនួន១៩.០០០រៀលនេះទៅលោកប្រាក់ សន វិញ ។

បង្គាប់ឱ្យលោកនង ស៊ុំ បង់ពន្ធសមាមាត្រតាមការកំណត់របស់សាលាឧទ្ធរណ៍ ។

៤. សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ ។